ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

**សារជូនពរ**

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ សាយ ឈុំ ប្រធានព្រឹទ្ធសភា**
**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល២០១៩**

**សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់** !

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ប្រកបដោយសេចក្តីសោមនស្សរីករាយ នៃទិវាចូលឆ្នាំថ្មីឆ្នាំសកល ២០១៩ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួន ខ្លាំងក្លា បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំព្រឹទ្ធសភាដែលជាស្ថាប័ននីតិប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា ឱ្យសម្រេចបាននូវលទ្ធផលត្រចះត្រចង់ថ្មីៗថែមទៀត។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរព និងស្វាមីភក្តិយ៉ាងជ្រាលជ្រៅបំផុត មិនអាចបំភ្លេចបានចំពោះសកម្មភាពស្នេហាជាតិប្រកបដោយគុណូបការៈដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ** តែងតែបានយកអស់កម្លាំងកាយចិត្ត និងរាល់បទពិសោធន៍ក្នុងការដឹកនាំព្រឹទ្ធសភា ឱ្យក្លាយជាស្ថាប័ននីតិប្បញ្ញត្តិមួយប្រកបដោយសក្តានុពល ដើម្បីនាំនាវាកម្ពុជាឆ្ពោះទៅរកនីតិរដ្ឋមួយដែលជាមូលដ្ឋានគ្រឹះ ធ្វើឱ្យប្រទេសជាតិមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងភាពសម្បូរសប្បាយរុងរឿងស្របតាមបំណងប្រាថ្នារបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ក្នុងនាមខ្ញុំនិងភរិយា សូមលើកហត្ថប្រណម្យចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោកសូមព្រះអង្គតាមជួយបីបាច់ថែរក្សាប្រោះព្រំសព្ទសាធុការពរជ័យ ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ** និង**លោកជំទាវ** ព្រមទាំងបុត្រាបុត្រី **ចៅប្រុសចៅស្រី**ជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០១៨
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**

វិថីហ្សកឌីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖០២៣ ៨៨៣ ២៧៤: generalsec@mod.gov.kh